ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
តុលាការព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦១៦ អ.ក
ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩
សំណុំរឿងស៊ើបសួរលេខ ១៦៤ ស.ស
ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ០៦៥ ជ.រ
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌលេខ ០១៧/ឈ
ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

កាលបរិច្ឆេទនៃសវនាការ ៖ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤។
សាលសវនាការ និងពេលវេលា ៖ សាល ១ ម៉ោង ៨ ព្រឹក។
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។
សាលសវនាការ និងពេលវេលា ៖ សាល ៥ ម៉ោង ២ រសៀល។
ក្រោមសមាសភាពជំនុំជម្រះ រួមមាន៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល និងជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ក. អំពីអត្តសញ្ញាណជនជាប់ចោទ**

១. ឈ្មោះ [redacted] **ណាន** ភេទប្រុស អាយុ ៥២ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អាជីវករ។
ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល។
ទីលំនៅភូមិ[redacted] ខេត្តកណ្ដាល។
ឪពុកឈ្មោះ [redacted]ណែម (ស) ម្ដាយឈ្មោះ [redacted] ថន (រ) ប្រពន្ធឈ្មោះ [redacted]សុខជា មានកូន ០៥ នាក់។
ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្រៅឃុំ)

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
ការិយាល័យផ្ទះលេខ១៤៤ ផ្លូវលេខ១៩៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

២. ឈ្មោះ [redacted] **សុខជា** ភេទស្រី អាយុ ៥៨ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អាជីវករ។
ទីកន្លែងកំណើតភូមិ[redacted] ខេត្តកណ្ដាល។



Scanned with CamScanner

ទីលំនៅភូមិ[redacted] ខេត្តកណ្តាល។

ឪពុកឈ្មោះ [redacted] អ៊ុម (ស) ម្តាយឈ្មោះ កាន់ ប៊ិន (ស) ប្តីឈ្មោះ [redacted] ណាន មានកូន ០៥ នាក់។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ គ្មាន។ (ក្រៅឃុំ)

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ១៤៤ ផ្លូវលេខ១៩៣ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យអាគារ៧៦ ជាន់ទី១ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

ត្រូវជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ រហូតមកដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

**ខ. អំពីអត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី**

១. ឈ្មោះ [redacted] **ស្រីពៅ** ភេទស្រី កើតឆ្នាំ១៩៦៩ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ លក់ផ្លែឈើ។

ទីលំនៅភូមិតាងៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាណាជាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ៥៣៤ អឺស្ទូឡ្យ ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាណាជាចក្រកម្ពុជា។

ការិយាល័យអាគារលេខ១១២បេ ផ្លូវលេខ១៧៣ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

២. ឈ្មោះ [redacted] **ចប** ភេទប្រុស កើតឆ្នាំ១៩៥៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ អាជីវកម្មខ្សាច់។

ទីលំនៅភូមិជ្រៃកោង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

**មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាណាជាចក្រកម្ពុជា។

ការិយាល័យផ្ទះលេខ៥៣៤ អឺស្ទូឡ្យ ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

**សំណុំរឿងព្រហ្មទណ្ឌនេះបានបញ្ជូនមកជំនុំជម្រះតាម ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៦០/២០ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលមាន៖**

**អង្គហេតុដែលប្តឹងមកតុលាការ**

កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ឈ្មោះ [redacted] ណាន ភេទប្រុស អាយុ ៥៣ ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សុខជា អាយុ ៥៨ ឆ្នាំ បានទទួលប្រាក់ពីឈ្មោះ [redacted] ចប ភេទប្រុស អាយុ ៦២ ឆ្នាំ និងឈ្មោះ [redacted] ស្រីពៅ ភេទស្រី អាយុ ៥១ ឆ្នាំ ចំនួន ៤២.៤០០ (បួនម៉ឺនពីរពាន់បួនរយ) ដុល្លារអាមេរិក ដោយធានាថា យកទៅទិញដីដែលមានក្បាលដីលេខ ២២០ មានទំហំ ៣ ហិកតា មានទីតាំងនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដោយមានអ្នកលក់ឈ្មោះ [redacted] អាន ភេទស្រី។ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ឈ្មោះ



Scanned with CamScanner

[redacted] ណាន និង [redacted] សុខជា បានយកប្រាក់ពីឈ្មោះ [redacted] ចប បន្ថែមទៀតចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក សរុបប្រាក់ទាំងអស់ចំនួន ៥២.៩០០ (ប្រាំម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ដោយជនទាំងពីរធានាធ្វើកិច្ចសន្យាលក់ដីផ្តាច់ និងផ្ទេរសិទ្ធិមកឱ្យ។ ក្រោយមកឈ្មោះ [redacted] ស្រីពៅ បានទៅធ្វើអាជីវកម្មបូមខ្សាច់លើដីនោះ ស្រាប់តែអ្នកដទៃមកទាមទារដីនោះថាជារបស់គេចំនួន ២០ អា ហើយជនខាងលើមិនបានដោះស្រាយឱ្យនោះទេ ដោយចេះតែយកលេសម្តងថ្ងៃនេះម្តងថ្ងៃនោះ ទូរស័ព្ទមិនលើក រហូតដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩។ ក្រោយមកទើបដឹងថា ឈ្មោះ [redacted] ណាន និងឈ្មោះ [redacted] សុខជា បានយកប្រាក់ទាំងនោះទៅដើរលេងស៊ីចាយ ហើយពុំមានដីលក់ និងមិនឱ្យជួបជាមួយម្ចាស់ដីដែលពួកគេបានអះអាងនោះទេ។

## អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

### ក. អំពីកិច្ចពិភាក្សាដេញដោលមុនពេលអង្គសេចក្តី

អំពីវិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ តាមមាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

អំពីអញ្ញត្រកម្ម តាមមាត្រា ៣៤២ ដល់មាត្រា ៣៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖ គ្មាន។

### ខ. អំពីកិច្ចពិភាក្សាដេញដោលលើអង្គសេចក្តី

**១. ការសួរចម្លើយជនជាប់ចោទ**

១.១. ចម្លើយជនជាប់ចោទឈ្មោះ [redacted] **ណាន** នៅចំពោះមុខតំណាងអយ្យការ៖ ខ្លួនមិនបានលក់ដីឱ្យទៅឈ្មោះ [redacted] ចប ភេទប្រុស និងឈ្មោះ [redacted] ស្រីពៅ ភេទស្រី នោះទេ ដីនេះឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស្រីពៅ បានទិញផ្ទាល់ពីឈ្មោះ [redacted] ស៊ូងាន ភេទប្រុស ជាម្ចាស់ដី ចំណែករូបខ្លួនគ្រាន់តែជាសាក្សី និងជូនគាត់ទាំងពីរនោះទៅទិញដីខាងលើនោះ។ ដីដែលទិញនោះមានទំហំ ១៨.២១០ មែត្រការ៉េ ទិញក្នុងតម្លៃ ៣.៥ ដុល្លារ ក្នុងមួយមែត្រការ៉េ សរុបជាប្រាក់មានចំនួន ៦៣.៧៣៥ ដុល្លារអាមេរិក ហើយឈ្មោះទាំងពីរនេះបានប្រគល់ប្រាក់ឱ្យទៅឈ្មោះ [redacted] ស៊ូអាន បានចំនួន ៥២.៩០០ ដុល្លារ នៅខ្វះ ១៨.៨៣៥ ដុល្លារ។ ដីដែលទិញនេះស្ថិតនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដីនេះជាដីទួលនៅមាត់ស្ទឹង ជាប្រភេទដីកាយយកខ្សាច់លក់។ ចំពោះលិខិតបានប្រគល់ប្រាក់ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ចំនួនសរុបទាំងមុនទាំងក្រោយ ៥២.៩០០ ដុល្លារអាមេរិក ខ្លួនបានផ្តិតមេដៃមែន ដោយសារឈ្មោះ [redacted] ចប គាត់ចង់ដឹងថា គាត់បានប្រគល់ប្រាក់បានប៉ុន្មានហើយ លាយល័ក្ខជាអក្សរ ហើយខ្លួនក៏បានផ្តិតមេដៃនៅលើលិខិតនេះទាំងប្តីប្រពន្ធ។ មូលហេតុដែលឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស្រីពៅ ឱ្យខ្លួនផ្តិតមេដៃលើលិខិតបានប្រគល់ប្រាក់ តាមការប្រាប់របស់ឈ្មោះ [redacted] ស៊ូអាន ជាម្ចាស់ដី។ ចាប់តាំងពីការទិញលក់ខាងលើរហូតដល់សព្វថ្ងៃនេះ ឈ្មោះ [redacted] ស៊ូអាន ពុំបានបដិសេធការទិញលក់ ឬការទទួលប្រាក់កន្លងមកនោះទេ។ រាល់ឯកសារទិញលក់ដី ខ្លួនមិនបានធ្វើទេ គឺឈ្មោះ [redacted] ស៊ូអាន ជាអ្នកធ្វើ។ ចំពោះរឿងនេះខ្លួនមិនបានលក់ដីឱ្យឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស្រីពៅទេ គឺឈ្មោះ [redacted] ស៊ូអាន ជាអ្នកលក់ដីគាត់ទេ ចំពោះភស្តុតាង និងឯកសារខ្លួននឹងដាក់ជូននៅពេលក្រោយ។ ចំពោះរឿងនេះខ្លួនសំណូមពរតម្កល់រឿងទុកឥតចាត់ការព្រោះខ្លួនមិនបានប្រព្រឹត្តដូចការប្តឹងនោះទេ។

១.២. ចម្លើយជនជាប់ចោទឈ្មោះ [redacted] **ណាន** នៅចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនស្គាល់ឈ្មោះ [redacted] ស្រីពៅ ព្រោះជាអ្នករកស៊ីបូមខ្សាច់។ កាលពីអំឡុងឆ្នាំ២០១១ ឈ្មោះ [redacted] ស្រីពៅ បានមកទិញដីឈ្មោះ [redacted] ស៊ូអាន ដែលមានលេខក្បាលដី ២២០ ទំហំ ១៨.២១០ ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ក្នុងតម្លៃបីដុល្លារកន្លះ ក្នុងមួយម៉ែត្រការ៉េ។ ក្នុងការលក់ទិញដី

ខាងលើនេះ គឺឈ្មោះ [redacted] ស្រីពៅ បានធ្វើការកក់ប្រាក់ចំនួន ២០.០០០ ដុល្លារ ទៅឱ្យឈ្មោះ [redacted] ស៊ូអាន ដែលជាម្ចាស់ដីដោយផ្ទាល់ ដូចមាននៅក្នុងកិច្ចសន្យាកក់ប្រាក់លក់ដី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១ ចំណែកខ្លួន គឺគ្រាន់តែជាអ្នកធ្វើសាក្សីនៅក្នុងកិច្ចសន្យានោះប៉ុណ្ណោះ។ បន្ទាប់ពីបានកក់ប្រាក់លើកទី១ រួចមក ឈ្មោះ [redacted] ស្រីពៅ បានចូលធ្វើអាជីវកម្មឬបខ្សាច់លើទីតាំងដីខាងលើតែម្ដង។ ក្រោយមកឈ្មោះ [redacted] ស្រីពៅ បានប្រគល់ប្រាក់ចំនួន ៣ លើកទៀត ដែលមានទឹកប្រាក់សរុបចំនួន ៣២.៨០០ ដុល្លារអាមេរិក មកឱ្យខ្លួន ដើម្បីប្រគល់ឱ្យឈ្មោះ [redacted] ស៊ូអាន ដែលជាម្ចាស់ដី។ ចំពោះប្រាក់ដែលឈ្មោះ [redacted] ស្រីពៅ ខ្វះបង្គ្រប់ថ្លៃដី គឺឈ្មោះ [redacted] ស្រីពៅ បានធ្វើកិច្ចសន្យាដាក់បញ្ចាំចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ ដោយមានការដឹងឮពីអាជ្ញាធរភូមិឃុំផងដែរ។ នៅក្នុងរឿងនេះម្ចាស់ដីឈ្មោះ [redacted] ស៊ូអាន មិនទាន់ទទួលបានប្រាក់គ្រប់ចំនួនថ្លៃការលក់ដីឡើយ ដូចនេះទើបមិនទាន់បានធ្វើការផ្ទេរកម្មសិទ្ធិឱ្យទៅឈ្មោះ [redacted] ស្រីពៅ វិញ។ ប្រាក់ដែលខ្លួនទទួលពីឈ្មោះ [redacted] ស្រីពៅ ចំនួន ៣២.៨០០ ដុល្លារ ខ្លួនបានប្រគល់ឱ្យឈ្មោះ [redacted] ស៊ូអាន រួចរាល់ហើយ។ នៅក្នុងរឿងនេះខ្លួនសូមឱ្យតុលាការកោះហៅឈ្មោះ [redacted] ស៊ូអាន ដើម្បីសាកសួរ។ ឈ្មោះ ជា ស៊ូអាន ភេទស្រី អាយុ ៨០ ឆ្នាំ ជាតិខ្មែរ រស់នៅបច្ចុប្បន្ននៅផ្ទះលេខ៥៣អឺ១ ផ្លូវ១០៧ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។ សូមបញ្ជាក់ថាឈ្មោះ [redacted] សុខជា ជាប្រពន្ធរបស់ខ្លួន ហើយគាត់មិនបានដឹងរឿងហេតុនៅក្នុងរឿងនេះឡើយ។ នៅក្នុងរឿងនេះខ្លួនសុំឱ្យតុលាការលើកលែងចោទប្រកាន់លើរូបខ្លួនផង។

**១.៤.** ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខជា** នៅចំពោះមុខតំណាងអយ្យការ៖ ចំពោះឈ្មោះ [redacted] ស្រីពៅ ឈ្មោះ [redacted] ចប ប្ដឹងចោទខ្លួនពីបទឆបោកនោះ ថាខ្លួនបានលក់ដីឱ្យគាត់ទាំងពីរនាក់នោះ ខ្លួនមិនបានដឹងទេ ហើយខ្លួនក៏មិនបានលក់ដែរ។ ការទិញលក់ដីខាងលើនោះ ខ្លួនមិនបានដឹងរឿងទេ ប្ដីខ្លួនជាអ្នកដឹងរឿង។ រីឯកសារប្រគល់ប្រាក់ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ គឺទៅជាមួយប្ដីខ្លួន ហើយគេឱ្យខ្លួនផ្ដិតមេដៃជាមួយគេតែម្ដង។ ចំពោះរឿងនេះខ្លួនសំណូមពរតម្កល់រឿងទុកឥតចាត់ការព្រោះ ខ្លួនមិនបានប្រព្រឹត្តដូចការប្ដឹងនោះទេ។

**១.៥.** ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខជា** នៅចំពោះមុខចៅក្រមស៊ើបសួរ៖ នៅក្នុងរឿងនេះខ្លួនមិនស្គាល់ឈ្មោះ [redacted] ស្រីពៅ ឡើយ ហើយក៏ពុំជាប់ពាក់ព័ន្ធនិងការទិញលក់ ឬធ្វើជាសាក្សីនៅក្នុងការទិញលក់ដីដែលមាននៅក្នុងសំណុំរឿងខាងលើនេះឡើយ។ ខ្លួន និងប្ដីឈ្មោះ [redacted] ណាន ធ្លាប់ផ្ដិតមេដៃបញ្ជាក់ថា បានទទួលលុយពីឈ្មោះ [redacted] ស្រីពៅ ដើម្បីយកទៅប្រគល់ឱ្យឈ្មោះ [redacted] ស៊ូអាន ដែលជាម្ចាស់ដីប៉ុណ្ណោះ។ សូមបញ្ជាក់ថា មូលហេតុដែលខ្លួនផ្ដិតមេដៃលើលិខិតប្រគល់ និងទទួលប្រាក់ទុកជូនឈ្មោះ [redacted] ស៊ូអាន ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ ព្រោះកាលនោះខ្លួនបានទៅជាមួយប្ដី ហើយពេលនោះមេធាវីរបស់ឈ្មោះ [redacted] ស្រីពៅ ក៏បានឱ្យខ្លួនផ្ដិតមេដៃដឹងឮលើលិខិតនោះដែរ។ ក្នុងរឿងនេះខ្លួនដឹងតែប៉ុណ្ណឹងទេ ក្រៅពីនេះមិនដឹងទេ។ នៅក្នុងរឿងនេះខ្លួនសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើរូបខ្លួនផង ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ។

**១.៦.** ចម្លើយជនជាប់ចោទឈ្មោះ [redacted] **សុខជា** ក្នុងកិច្ចពិភាក្សាដេញដោល៖ ខ្លួនបានដឹងត្រឹមតែការទិញលក់របស់គាត់។ ខ្លួនស្គាល់ឈ្មោះ [redacted] ចប ស្រពិចស្រពិល ចំណែកឈ្មោះ [redacted] ស្រីពៅ ខ្លួនស្គាល់បែបស្រពិចស្រពិលដែរ។ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ ខ្លួនដឹងថា មានការប្រគល់ប្រាក់ថ្លៃទិញលក់ដី លុយចំនួន ៤២.៨០០ (បួនម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ប្ដីខ្លួនប្រាប់ថា ជាលុយទិញលក់ដី ជាដីរបស់ឈ្មោះ [redacted]



Scanned with CamScanner

ស៊ូអាន ជាម្ចាស់ដី។ ខ្លួនដឹងថា ត្រឹមតែជាដីរបស់ឈ្មោះ [redacted] ស៊ូអាន ហើយលុយកក់នោះម្ចាស់ដីមកទទួលលុយខ្លួនគាត់ផ្ទាល់។ ចំណែកអ្នកលក់ឈ្មោះ [redacted] ចប។ ប្តីខ្លួនឈ្មោះ [redacted] ណាន ជាអ្នកឈ្មួញកណ្តាលដែរ។ អ្នកលក់ និងអ្នកទិញមកតទល់គ្នាតែម្តង។ ពីដំបូងឈ្មោះ [redacted] ចប បានកាយខ្សាច់ដោយមិនទាន់ឱ្យប្រាក់ទៅអ្នកលក់គ្រប់។ ថ្ងៃប្រគល់ប្រាក់ខ្លួនមិននៅទេដោយសារតែរវល់ដាំបាយ។ ការទិញលក់ គឺរវាងអ្នកលក់ និងអ្នកទិញដែលមកតទល់គ្នាតែម្តង។ ការផ្តិតមេដៃ គឺប្តីខ្លួនជាអ្នកឱ្យផ្តិត ខ្លួនគ្រាន់តែផ្តិតតាមប្តីខ្លួនតែមិនចាំថាឯកសារអ្វីនោះទេ គ្រាន់តែប្តីខ្លួនប្រាប់ថាសរុបថ្លៃដី តែលុយខ្លួនមិនបានទទួលនោះទេ ។ ការទិញលក់ដីទំហំក្បាលលេខ ២២០ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ខ្លួនមិនដឹងទីតាំងដីទេ។ ឈ្មោះ [redacted] ចប គឺអ្នកទិញ អ្នកលក់ឈ្មោះ [redacted] ស៊ូអាន ខ្លួនស្គាល់តាមប្តីនៅអំឡុងឆ្នាំ២០១២។ ចំពោះការប្រគល់ទទួលលុយខ្លួនមិនបានដឹងទេ គឺតែកក់ទេ លក់គឺអ្នកលក់ និងអ្នកទិញតទល់គ្នា។ ការផ្តិតមេដៃលើលិខិតប្រគល់ទទួលប្រាក់ឆ្នាំ២០១៩ គឺប្តីខ្លួនប្រាប់ថា អ្នកលក់បានប្រគល់លុយឱ្យម្ចាស់ដី ហើយឱ្យម្ចាស់ដីថា "បងឯងផ្តិតទៅ ជួយដឹងឮវិញទៅ"។ ដោយស្មានថា ជាសាក្សី ហើយលុយក៏មិនឱ្យគ្រប់ដែរ ម្តងបន្តិចៗ។ ខ្លួនមិនមែនជាអ្នកលក់ដីទេ។ ខ្លួនមិនមែនជាម្ចាស់ដី។ លិខិតចុះថ្ងៃទី ៣ ខែសីហា ឆ្នាំ២០១៩ គឺផ្តិតគ្រាន់តែជាសាក្សីដឹងឮប៉ុណ្ណោះ។ ឈ្មោះ [redacted] ចប ខ្លួនស្គាល់ពេលទិញដី។ ឯកសារដែលខ្លួន ផ្តិតគឺខ្លួនមិនបានអានទេ គឺរាល់ឯកសារដែលខ្លួនបានផ្តិតគឺ ខ្លួនមិនបានអានទាំងអស់។ ពេលធ្វើកិច្ចសន្យាប្រគល់លុយចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ខ្លួនមិនបានទទួលលុយ។ ឆ្នាំ២០១៩ លុយទាំង ៤០០០០ (បួនម៉ឺន) ដុល្លារអាមេរិក ខ្លួនមិនបានទទួលលុយទេ។ ការទិញលក់រវាងឈ្មោះ [redacted] ចប និងឈ្មោះ ជា ស៊ូអាន គឺគេធ្វើឡើងរវាងអ្នកទាំងពីរ។ ខ្លួនគ្រាន់តែផ្តិតមេដៃលុយគឺខ្លួនមិនបានទទួលទេ។ ឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស៊ូអាន គឺអ្នកទិញលក់ ហើយឈ្មោះ [redacted] ចប ជាអ្នកបូមខ្សាច់ ពីដើមប្តីខ្លួនប្រាប់ថា កក់លុយ ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ឈ្មោះ [redacted] ចប មកបូមខ្សាច់តែម្តង។ ខ្លួនផ្តិតមេដៃដោយសារប្តីប្រាប់ថា សរុបលុយតែម្តង។ បច្ចុប្បន្ននេះ ប្តីខ្លួន បានស្លាប់បាត់ហើយ។

**២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**

**២.១.** ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចប** នៅចំពោះមុខតំណាងអយ្យការ៖ ខ្លួនសូមរក្សាយកចម្លើយដូចនៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ទុកជាបានការទាំងអស់ និងសុំយកចម្លើយដូចប្អូនខ្លួនឈ្មោះ [redacted] ស្រីពៅ ឆ្លើយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ទុកជាបានការទាំងអស់ ព្រោះដីដែលទិញនេះ ខ្លួន និងប្អូនស្រីបានទិញរួមគ្នា។ ចំពោះរឿងនេះ ខ្លួនសំណូមពរដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩។

**២.២.** ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ចប** នៅចំពោះមុខចៅក្រមស៊ើបសួរ៖ ខ្លួនស្គាល់ឈ្មោះ ណែម ណាន ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] សុខជា ព្រោះអ្នកទាំងពីរជាអ្នកលក់ដីឱ្យខ្លួន។ កាលពីអំឡុងឆ្នាំ២០១២ ខ្លួនបានឱ្យឈ្មោះ [redacted] ណាន ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] សុខជា ទិញដីឱ្យខ្លួនបានទំហំ ០៣ ហិចតា ដែលមានទីតាំងស្ថិតនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ក្នុងតម្លៃ ២ (ពីរដុល្លារ/ម៉ែត្រការ៉េ) សរុប ៦០.០០០ (ប្រាំមួយម៉ឺន) ដុល្លារអាមេរិក គឺទិញដើម្បីធ្វើអាជីវកម្មខ្សាច់។ សូមបញ្ជាក់ថា ដីទីទាំងខាងលើនេះ គឺពីមុនមកធ្លាប់មានក្រុមហ៊ុនផ្សេងធ្វើអាជីវកម្មលើដីនោះម្តងហើយ។



Scanned with CamScanner

ក្រោយមកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ខ្លួនបានប្រគល់ប្រាក់លើកទី១ ឱ្យទៅឈ្មោះ [redacted] ណាន ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] សុខជា ចំនួន ៤២.៨០០ (បួនម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក និងលើកទី២ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១២ ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើម្បីឱ្យអ្នកទាំងពីរទិញដីខាងលើឱ្យខ្លួន សរុបទឹកប្រាក់ចំនួន ៥២.៨០០ (ប្រាំម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក។ ពេលដែលខ្លួនបានប្រគល់ប្រាក់ខាងលើ ឱ្យទៅឈ្មោះ [redacted] ណាន និងប្រពន្ធឈ្មោះ [redacted] សុខជា រួចមក អ្នកទាំងពីរនោះមិនព្រមធ្វើការផ្ទេរសិទ្ធិលើដីខាងលើឡើយ ហើយបានធ្វើការគេចវេសរហូត។ ពេលដែលខ្លួនទាក់ទងទៅក៏មិនចូលទៀត។ ពេលដែលខ្លួនជួបម្ចាស់ដើមនៃដីនោះគឺឈ្មោះ [redacted] ណាន មិនព្រមឱ្យខ្លួនជួបជាមួយម្ចាស់ដីដើមឡើយ។ ពេលដែលខ្លួនសួរទៅឈ្មោះ [redacted] ណាន ថាតើពេលណាទើបធ្វើការផ្ទេរសិទ្ធិលើដីដែលខ្លួនបានទិញខាងលើ។ ឈ្មោះ [redacted] ណាន និងប្រពន្ធបានយកលេសថា ខ្លួនមិនទាន់ប្រគល់លុយគ្រប់ចំនួនឱ្យគាត់។ ប៉ុន្តែចំពោះលុយដែលខ្លួនខ្វះប្រហែលជា ប្រាំពីរពាន់ដុល្លារ នោះ គឺទាល់តែគាត់ផ្ទេរសិទ្ធិឱ្យខ្លួន ទើបខ្លួនប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅគាត់។ សូមបញ្ជាក់ថា កាលពីខ្លួនប្រគល់ប្រាក់លើកដំបូងឱ្យទៅឈ្មោះ [redacted] ណាន និងប្រពន្ធឈ្មោះ [redacted] សុខជា កាលពីលើកទី១ គឺខ្លួនចូលទៅធ្វើអាជីវកម្មបូមខ្សាច់លើដីដែលទិញខាងលើហើយ។ លុះក្រោយមកពេលដែលកំពុងធ្វើអាជីវកម្មលើដីទំហំ ៣ ហិចតា បានទិញនោះ ក៏ស្រាប់តែមានអ្នកផ្សេងទៀតមកធ្វើការអះអាងថា ដីនោះជាដីរបស់គេមួយចំណែក។ ចំណែកខ្លួនក៏មិនបានធ្វើអាជីវកម្មលើដីនោះបន្តទៀតដែរ ព្រោះដីដែលសល់ប្រហែលជាមួយហិចតាកន្លះនោះគឺដីរណ្ដៅចាស់។ ក្រោយពីម្ចាស់ដីផ្សេងមកធ្វើការអះអាងខាងលើខ្លួនបានធ្វើការទាក់ទងទៅឈ្មោះ [redacted] ណាន និងប្រពន្ធឈ្មោះ [redacted] សុខជា ដើម្បីដោះស្រាយ ប៉ុន្តែអ្នកទាំងពីរនោះ គាត់ថាដីនោះជាដីរបស់គេទេ ឱ្យគេវិញទៅ។ សូមបញ្ជាក់ថា ដីដែលឈ្មោះ [redacted] ណាន និងប្រពន្ធឈ្មោះ [redacted] សុខជា ទិញឱ្យខ្លួនគឺមានឈ្មោះ [redacted] ស៊ូអាន ភេទស្រី។ នៅក្នុងរឿងនេះឈ្មោះ [redacted] ណាន និងប្រពន្ធឈ្មោះ [redacted] សុខជា បានលក់ដីខ្យល់ឱ្យមកខ្លួន

**៣. ការស្ដាប់ចម្លើយសាក្សី**

**៣.១.** ចម្លើយសាក្សីឈ្មោះ [redacted] **សឿន** ចំពោះមុខតំណាងអយ្យការ៖ ខ្លួនដឹងថាដីនេះជាដីរបស់ឈ្មោះ [redacted] សុភឿន និងឈ្មោះ [redacted] សមន្ថា ដែលបានទិញពីប្រជាជននៅក្នុងភូមិស្រែតាមែន ឃុំទំនប់ធំ ស្រុកពញាឮ ខេត្តកណ្ដាល ដែលមានទំហំ ០៤ ហិចតា។ ចំពោះដីនេះខ្លួនបានឃើញថាឈ្មោះ [redacted] សំណាង បានទៅធ្វើរបងនៅដីនេះ នៅពេលដែលខ្លួនបានសួរនាំឈ្មោះ [redacted] សំណាង បាននិយាយថាខ្លួនទិញពីឈ្មោះ [redacted] សមន្ថា និងឈ្មោះ [redacted] សុភឿន ហើយ។ ខ្លួនបានដឹងថាឈ្មោះ [redacted] សុភឿន បានយកប្លង់ដីនេះទៅដាក់នៅធនាគារប្រៃសណីយ៍ ដើម្បីយកប្រាក់ចំនួន ០៥ ម៉ឺនដុល្លារអាមេរិក។ ចំពោះកិច្ចសន្យាផ្ទេរសិទ្ធិគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ហើយលិខិតផ្ទេរសិទ្ធិនេះខ្លួនបានចុះហត្ថលេខាពិតមែន តែមិនបានចុះហត្ថលេខានៅចំពោះមុខភាគីទាំងសងខាងទេ ប៉ុន្តែខ្លួនបានឃើញមានស្នាមមេដៃផ្ទេរសិទ្ធិ និងមានហត្ថលេខាមេឃុំរួចជាស្រេចហើយ ទើបពេលនោះខ្លួនក៏បានចុះហត្ថលេខា។ ក្នុងរឿងនេះខ្លួនពុំបានដឹងឮអ្វីផ្សេងទៀតនោះទេ ខ្លួនសូមអស់។ រាល់ការបំភ្លឺរបស់ខ្លួន ខ្លួនយល់ព្រមទទួលខុសត្រូវចំពោះមុខច្បាប់។



Scanned with CamScanner

## សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

ក. ការកត់សម្គាល់ខ្លីៗរបស់៖

១. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីពៅ៖ អវត្តមាន។

២. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចប៖ អវត្តមាន។

៣. ជនជាប់ចោទឈ្មោះ [redacted] សុខជា៖ អវត្តមាន។

៤. ជនជាប់ចោទឈ្មោះ [redacted] ណាន៖ សំណូមពរតុលាការរកយុត្តិធម៌ឱ្យខ្លួនផង។

ខ. សេចក្តីសន្និដ្ឋាន៖

១. សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖

ក្រោយពីស្តាប់ការសាកសួរដេញដោល ជនជាប់ចោទបដិសេធ ហើយគឺខ្លួនគ្រាន់តែជាសាក្សី និងប្តីខ្លួនជាអ្នកគួកជេរ តាមឯកសារជនជាប់ចោទបានផ្តិតមេដៃប្រគល់ទទួលប្រាក់អាចជាអ្នកធ្វើកិច្ចសន្យាផ្ទាល់ ហេតុនេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរ។

២. សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ៖

លោក [redacted] សេងហ៊ន៖ ការទិញលក់ដីក្បាល ២២០ ចំនួន ១០.០០០ ម៉ែត្រការ៉េជាង ទិញក្នុងអំឡុងឆ្នាំ ២០២១ ខែកញ្ញា ថ្ងៃទី៧ ផ្អែកតាមអង្គហេតុការប្រគល់ប្រាក់ ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ចំពោះលិខិតប្រគល់ទទួលថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ គឺមិនមានការប្រគល់ប្រាក់ជាក់ស្តែងទេ ស្នើសុំតុលាការពិនិត្យលើអាជ្ញាយុកាល ហើយឈ្មោះ [redacted] ណាន ទទួលមរណៈភាព។ ឈ្មោះ [redacted] សុខជា មិនបានលក់ដីឱ្យឡើយ ហើយគាត់មិនបានដឹងរឿង។ ការផ្តិតមេដៃថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៩ គាត់ផ្តិតតាមប្តីរបស់គាត់។ ជាក់ស្តែងគាត់មិនបានដឹងពីឯកសារដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលការផ្ទេរសិទ្ធិ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្រគល់ប្រាក់គ្រប់។ ចំណុចទាំងអស់នេះមានវិមតិសង្ស័យ ស្នើសុំរំលត់បណ្តឹងអាជ្ញាលើឈ្មោះ [redacted] ណាន ទី២ សម្រេចឱ្យឈ្មោះ [redacted] សុខជា រួចពីបទ រំលោភលើទំនុកចិត្ត។

លោក [redacted] វេលស៊ី៖ ហេតុការណ៍គឺឈ្មោះ [redacted] សុខជា មិនស្គាល់ឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស្រីពៅ ស្គាល់តាមរយៈអ្វី។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ក្នុងលិខិតបញ្ចាំ ហើយបានប្រគល់ប្រាក់ឱ្យម្ចាស់ដី ហើយសល់ប្រាក់គឺបញ្ចាំ ហើយមិនបានប្រគល់ប្រាក់គ្រប់ឱ្យឈ្មោះ [redacted] ស៊ូអាន អង្គហេតុគឺដើមបណ្តឹងទិញពីឈ្មោះ [redacted] ស៊ូអាន មិនមែនទិញពីកូនក្តី។ ដោយផ្អែកតាមកិច្ចសន្យាចុះឆ្នាំ២០១១ ប៉ុន្តែដោយសារដើមបណ្តឹងរដ្ឋប្បវេណីមិនមានប្រាក់គ្រប់ពេល ទើបម្ចាស់ដីមិនអាចផ្ទេរដីឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដោយសារដើមបណ្តឹងរដ្ឋប្បវេណីទិញលក់ដោយសារកូនក្តីខ្លួនជាអ្នកគួកជេរ ហើយបង្ខំឱ្យផ្តិតមេដៃដែលនៅឆ្នាំ២០១៩ មានរយៈពេល ៨ ឆ្នាំ តើអាជ្ញាយុកាលនៃបទមជ្ឈិមតើផុតឬទេ។ កូនក្តីខ្ញុំជាអ្នកទទួលកម្រៃជើងសារ មូលហេតុអ្វីមិនប្តឹងម្ចាស់ដី។ ប្រសិនកូនក្តីខ្លួនជាគំនិតទុច្ចរិត ហើយឃើញថាកូនក្តីខ្ញុំបាទសុច្ចរិតក្នុងការទិញលក់ដីរបស់អ្នកលក់ឈ្មោះ ជា ស៊ូអាន និងអ្នកទិញឈ្មោះ [redacted] ចប។ ហេតុនេះស្នើសុំតុលាការរំលត់បណ្តឹងអាជ្ញាលើកូនក្តីខ្លួន។

- *ក្រោយពីបាន ស្តាប់កិច្ចពិភាក្សាដេញដោលរួចហើយ*

- *ក្រោយពីបាន ស្តាប់សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល*



Scanned with CamScanner

## សំអាងហេតុ

**ក. អំពីសមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តី**

សាលាដំបូងខេត្តកណ្តាលបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១២៨២ អ.ក** ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ណាន** ភេទប្រុស អាយុ ៥២ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ និងឈ្មោះ [redacted] **សុខជា** ភេទស្រី អាយុ ៥៨ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ មកជំនុំជម្រះពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ រហូតមកដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាលមានសមត្ថកិច្ចក្នុងការជំនុំជម្រះ៕

**ខ. អំពីដែនកំណត់នៃការប្តឹងចំពោះអង្គហេតុ និងបុគ្គល**

ដែនកំណត់នៃការប្តឹងទៅតុលាការចំពោះអង្គហេតុ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងទៅតុលាការចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យសាលាដំបូងខេត្តកណ្តាល មានសមត្ថកិច្ចក្នុងការជំនុំជម្រះលើ អង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] **ណាន** និងឈ្មោះ [redacted] **សុខជា** ៕

**គ. អំពី ពិរុទ្ធភាព**

១. អង្គហេតុដែលប្តឹងមកតុលាការ គឺជាអង្គហេតុដែលមានខ្លឹមសារថា "កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ឈ្មោះ [redacted] ណាន និងប្រពន្ធឈ្មោះ [redacted] សុខជា បានទទួលប្រាក់ពីឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស្រីពៅ ចំនួន ៤២.៩០០ (បួនម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ដោយធានាថា យកទៅទិញដីដែលមានក្បាលដីលេខ ២២០ មានទំហំ ៣ ហិកតា មានទីតាំងនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដោយមានអ្នកលក់ឈ្មោះ [redacted] អាន។ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ឈ្មោះ [redacted] ណាន និងឈ្មោះ [redacted] សុខជា បានយកប្រាក់ពីឈ្មោះ [redacted] ចប បន្ថែមទៀតចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក សរុបប្រាក់ទាំងអស់ចំនួន ៥២.៩០០ (ប្រាំម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ដោយជនទាំងពីរធានាធ្វើកិច្ចសន្យាលក់ដីផ្តាច់ និងផ្ទេរសិទ្ធិមកឱ្យ។ ក្រោយមកឈ្មោះ [redacted] ស្រីពៅ បានទៅធ្វើអាជីវកម្មបូមខ្សាច់លើដីនោះ ស្រាប់តែអ្នកដទៃមកទាមទារដីនោះថាជារបស់គេចំនួន ២០ អា ហើយជនខាងលើមិនបានដោះស្រាយឱ្យនោះទេ ដោយចេះតែយកលេសម្តងថ្ងៃនេះម្តងថ្ងៃនោះ ទូរស័ព្ទមិនលើក រហូតដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩។ ក្រោយមកទើបដឹងថា ឈ្មោះ [redacted] ណាន និងឈ្មោះ [redacted] សុខជា បានយកប្រាក់ទាំងនោះទៅដើរលេងស៊ីចាយ ហើយពុំមានដីលក់ និងមិនឱ្យជួបជាមួយម្ចាស់ដីដែលពួកគេបានអះអាងនោះទេ។" អង្គហេតុនេះ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ រហូតមកដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ៕



Scanned with CamScanner

២. តាមលិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ និងលិខិតប្រគល់និងទទួលប្រាក់ទុកជូនឈ្មោះ [redacted] ស៊ូអាន ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ តុលាការយល់ឃើញថា ចន្លោះពេលនៃលិខិតទាំងពីរនេះ មានរយៈពេល ៦ (ប្រាំមួយ) ឆ្នាំ ១០ (ដប់) ខែ ២៨ (ម្ភៃប្រាំបី) ថ្ងៃ។ ដោយឡែក បើពិនិត្យត្រឹមតែខ្លឹមសារនៃលិខិតប្រគល់ទទួលប្រាក់ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ តែឯកឯង មិនអាចឱ្យតុលាការដឹងបានថា តើប្រាក់ចំនួន ៥២.៩០០ (ប្រាំម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក ជាប្រាក់អ្វីនោះទេ ប៉ុន្តែបើធ្វើការពិនិត្យលើខ្លឹមសារនៃលិខិតប្រគល់និងទទួលប្រាក់ទុកជូនឈ្មោះ [redacted] ស៊ូអាន ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩ ទើបអាចដឹងថា ប្រាក់ចំនួន ៥២.៩០០ (ប្រាំម៉ឺនពីរពាន់ប្រាំបួនរយ) ដុល្លារអាមេរិក គឺជាប្រាក់ដែលជនជាប់ចោទបានទទួលពីឈ្មោះ [redacted] ចប និងឈ្មោះ [redacted] ស្រីពៅ ក្នុងការទិញរណ្ដៅខ្សាច់ពីឈ្មោះ [redacted] ស៊ូអាន។ ប៉ុន្តែតាមអង្គហេតុដែលប្ដឹងមកតុលាការ និងកាលបរិច្ឆេទនៃការចោទប្រកាន់ឃើញថា បានចោទប្រកាន់ជនជាប់ចោទពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងកំណត់កាលបរិច្ឆេទនៃការប្រព្រឹត្តគឺ **កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ រហូតមកដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៩**។ ចំណុចនេះ ជាចំណុចមិនត្រឹមត្រូវ ព្រោះអង្គហេតុនៃលិខិតទាំងពីរនេះ គឺដាច់ពីរគ្នា និងមានរយៈពេលទៅដល់ ៦ (ប្រាំមួយ) ឆ្នាំ ១០ (ដប់) ខែ ២៨ (ម្ភៃប្រាំបី) ថ្ងៃ។ បន្ថែមពីនេះ ដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ពាក្យបណ្ដឹងចូលមកអយ្យការអមសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩។ គិតចាប់ពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ មានរយៈពេល ៧ (ប្រាំពីរ) ឆ្នាំ ៥ (ប្រាំ) ខែ ២៧ (ម្ភៃប្រាំពីរ) ថ្ងៃ។ ហេតុនេះ បណ្ដឹងនេះធ្វើឡើងដោយផុតអាជ្ញាយុកាលនៃបទល្មើសចំពោះបទមជ្ឈិមតាមមាត្រា មាត្រា ៧ និងមាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. ដោយឡែក តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ តេង សុខជា បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ **ណែម ណាន** បានទទួលមរណភាព ប៉ុន្តែពុំបានដាក់ឯកសារដែលពាក់ព័ន្ធមកតុលាការនោះទេ។

**ឃ. អំពី បណ្ដឹងរដ្ឋប្បវេណី**

ដោយហេ[redacted] ជនជាប់ចោទត្រូវសម្រេចឱ្យបញ្ឈប់ការចោទប្រកាន់ ដោយមូលហេតុការផុតអាជ្ញាយុកាលនៃបទល្មើស[redacted]ហេតុនេះ តុលាការសម្រេចច្រានចោលការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

**សេចក្ដីសម្រេច**

**ក. បញ្ឈប់ការចោទប្រកាន់លើជនជាប់ចោទ៖**

១. ឈ្មោះ [redacted] **ណាន** ភេទប្រុស អាយុ ៥២ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ រហូតមកដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៧ មាត្រា ១០ នៃក្រមនិតិវិធីព្រហ្មទណ្ឌ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើស។

២. ឈ្មោះ [redacted] **សុខជា** ភេទស្រី អាយុ ៥៨ ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ពីបទ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ



ឯកសារចម្លងត្រឹមត្រូវតាមច្បាប់ដើម
តាខ្មៅ ថ្ងៃទី 16 ខែ 8 ឆ្នាំ 2024
ក្រឡាបញ្ជី

២០១២ រហូតមកដល់ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៧ មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើស។

ខ. ច្រានចោលការទាមទារសំណងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

*សំណុំរឿងព្រហ្មទណ្ឌនេះ ជំនុំជម្រះជាសាធារណៈនៅចាត់ទុកថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី/ នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខជា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណាន។*

*សាលក្រមព្រហ្មទណ្ឌនេះ ប្រកាសជាសាធារណៈ នៅថ្ងៃ ពុធ ៦ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ២ រសៀល នៅសាលសវនាការលេខ ៥។*

*ភាគីដែលមានបំណងធ្វើបណ្តឹងទាស់ ឬបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ត្រូវធ្វើបណ្តឹងទាស់ និងបណ្តឹងឧទ្ធរណ៍នេះ តាមការកំណត់របស់ច្បាប់។*

| | |
|---|---|
| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
| **ហត្ថលេខា និងត្រា** [redacted] | **ហត្ថលេខា និងត្រា** [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ ពុធ ៦ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្តាល, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**កណ្តាល, ថ្ងៃទី** 30 **ខែ** មករា **ឆ្នាំ** 2024

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner